ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៧ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ការសាងសង់អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងការសាងសង់អាកាសយានដ្ឋានដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ការសាងសង់អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងការសាងសង់អាកាសយានដ្ឋានដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **តឹករ៉េត សំរេច** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. | ឯកឧត្តម **ជា ឆ៊ាន់ដេត** | | អនុប្រធាន |
| ៣. | ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៤. | ឯកឧត្តម **ឱ តាយី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥. | ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦. | ឯកឧត្តម **ផេង សុវិជ្ជានោ** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៧. | ឯកឧត្តម **សរ សុវណ្ណា** | រដ្ឋលេខាធិការក្រសួងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨. | ឯកឧត្តម **គង់ ទិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |

| | | | |
|---|---|---|---|
| ៩. ឯកឧត្តម | **សយ សុខាន់** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន<br>អាកាសចរស៊ីវិល | សមាជិក |
| ១០.ឯកឧត្តម | **នុត អ៊ុនវ័ណ្ណារ៉ា** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា<br>នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១.ឯកឧត្តម | **គង់ ច័ន្ទវាសនា** | ទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី<br>និងជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ១២.ឯកឧត្តម | **ហាក់ សុខហេង** | អគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់<br>នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣. លោក | **ជេន ផាត** | ប្រធាននាយកដ្ឋានអនុលោមភាព និងត្រួតពិនិត្យ<br>នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក |
| ១៤. លោកស្រី | **សេង សុមេត្តា** | ប្រធានការិយាល័យនៃនាយកដ្ឋានផ្គត់ផ្គង់និង<br>ហិរញ្ញកិច្ច នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥. លោក | **ថោង ជ័យវាសនា** | អនុប្រធាននាយកដ្ឋានការងារស្រាវជ្រាវ ផ្សព្វផ្សាយ<br>និងព័ត៌មានវិទ្យាអគ្គលេខាធិការដ្ឋាននៃវេទិកាសម្ព័ន្ធ<br>សង្គមស៊ីវិល | សមាជិក |
| ១៦. លោក | **ស៊ីម វិសេស** | អនុប្រធានការិយាល័យនៃនាយកដ្ឋានទំនាក់ទំនង<br>អន្តរជាតិនៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៧. លោក | **ឌី មិថុ** | មន្ត្រីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក។ |

**ប្រការ ២.-**

គណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ការសាងសង់អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងការសាងសង់អាកាសយានដ្ឋានដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចដូចខាងក្រោម៖

- តាមដានត្រួតពិនិត្យនិងត្រួតពិនិត្យឡើងវិញ ការងារប្រភេទសាងសង់អគារ ដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- តាមដានត្រួតពិនិត្យនិងត្រួតពិនិត្យឡើងវិញ រាល់បញ្ហាដែលពាក់ព័ន្ធនឹង សម្ភារៈបច្ចេកទេសទាក់ទិននឹងការគ្រប់គ្រងនៃចលនាអាកាសយាន ជាសមត្ថកិច្ចរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- តាមដានត្រួតពិនិត្យនិងត្រួតពិនិត្យឡើងវិញ ផ្នែកបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ ទេពកោសល្យស៊ីវិល ដែលជាសមត្ថកិច្ចរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- សម្របសម្រួលជាទូទៅ ការងារអភិវឌ្ឍ និងសាងសង់អាកាសយានដ្ឋានខាងលើ ដែលជាសមត្ថកិច្ចរបស់គណៈកម្មការនេះដោយមានតំណាងក្រសួង ស្ថាប័ន នានា ជាអ្នកទទួលខុសត្រូវ
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីការវិវឌ្ឍនៃការសាងសង់ អាកាសយានដ្ឋានទាំងនេះដើម្បីពិនិត្យ និងមានវិធានការទាន់ពេលវេលា
- អនុវត្តភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣.-**

គណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ការសាងសង់អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងការសាងសង់អាកាសយានដ្ឋានដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញ ដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងផ្តល់យោបល់តាមការចាំបាច់។

គណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ការសាងសង់អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងការសាងសង់អាកាសយានដ្ឋានដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារ តាមការចាំបាច់។

**ប្រការ ៤.-**

សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ